| |
|---|
| តុលាការខេត្តបាត់ដំបង |
| សំណុំរឿងព្រហ្មទណ្ឌ |
| លេខ ៩៣៤ ចុះថ្ងៃទី ២១ |
| ខែ វិច្ឆិកា ឆ្នាំ ២០០៥ |
| សាលក្រម |
| លេខ ៣៨ ក ចុះថ្ងៃទី ១៧ |
| ខែ កុម្ភៈ ឆ្នាំ ២០០៦ |

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៩៣៤ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ផ សត ភេទប្រុស អាយុ ៤២ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបរ រកស៊ីធ្វើស្រែ មានទីកន្លែងកំណើតនៅភូមិតាម៉ែន ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី ៥ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិកាប់គោថ្មី ឃុំអូរចារ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ ឋ ម (រ) មានកូន ០២នាក់ មានឪពុកឈ្មោះ ផ (ស) មានម្តាយឈ្មោះ ឃ ជ (រ) ទោសពីមុន *គ្មាន* ។

ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នៅចំណុចផ្ទះរបស់ជនជាប់ចោទភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងអគារឃុំខ្លួន នៃពន្ធនាគារខេត្តបាត់ដំបង តាមដីកាឃុំខ្លួនលេខ ៥៨៨ ដឃខ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

ត្រូវជាប់ចោទពីបទ **បង្ករបួសស្នាមដោយចេតនាមានអាវុធ** តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

**អាណាព្យាបាលជនរងគ្រោះ**

ឈ្មោះ ឋ អ ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

មិនប្តឹងទារសំណងទេ សុំអោយតុលាការជួយសម្រាលទោស និង ដោះលែង

ជនជាប់ចោទ ។

## ជនរងគ្រោះ

-ឈ្មោះ ខ ត ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរមានទីលំនៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ វេលាម៉ោង ៧:០០យប់ នៅចំណុចភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ជនជាប់ចោទឈ្មោះ ផ សត បានប្រើពូថៅវាយទៅលើជនរងគ្រោះឈ្មោះ ខ ត ខាងសំប៉ែតផ្លែពូថៅ ចំថ្ងាសខាងឆ្វេងបណ្តាលអោយបែកឈាមដួលសន្លប់ ដោយខឹងនឹងជនរងគ្រោះឈ្មោះ ខ ត ស្រែកឡូឡា និង និយាយអោយក្ត ។

-តាមរបាយការណ៍ព្រឹត្តិហេតុលេខ ០១៦/០៥ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ប៉ូលីសនគរបាលរដ្ឋបាល ឃុំអូរដា បានបញ្ជាក់ថា កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ វេលាម៉ោង ៧:០០យប់ នៅចំណុចភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង មានករណីបង្ករបួសស្នាមកើតឡើង បង្កដោយឈ្មោះ ផ សត បានប្រើពូថៅវាយទៅលើឈ្មោះ ខ ត បណ្តាលអោយរបួសយ៉ាងធ្ងន់ ។

-តាមដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ១០៦ ៣ស.ព្រទ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបអង្កេត បានសំរេចចោទប្រកាន់លើឈ្មោះ ផ សត ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ មកជំនុំជំរះតាមច្បាប់ ។

## នៅចំពោះមុខតុលាការពេលសវនាការ

ឈ្មោះ ផ សត ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថា សមត្ថកិច្ចចាប់ខ្លួនខ្ញុំបាទនៅថ្ងៃខែមិនចាំទេ មូលហេតុខ្ញុំបាទវាយក្មួយខ្ញុំនៅវេលាម៉ោង ៧:០០ ទៅ ៨:០០នាទីយប់ ដោយវាយនឹងពូថៅខាងសំប៉ែតផ្លែពូថៅ ដោយពុំដឹងត្រូវកន្លែងណាទេ ពេលនោះក្មួយខ្ញុំឈ្មោះ ខ ត សន្លប់ ។ មូលហេតុខ្ញុំវាយក្មួយខ្ញុំដោយវាស្រែកឡូឡា ពូថៅនោះខ្ញុំដើរទៅបត់ជើងជ្រុះនៅកន្លែងបត់ជើង ។

ឈ្មោះ ម អ ជាអាណាព្យាបាលជនរងគ្រោះបានបញ្ជាក់ឆ្លើយថា នាងខ្ញុំត្រូវជាម្តាយឈ្មោះ ខ ត ខ្ញុំមិនបានឃើញឈ្មោះ ផ សត វាយកូនខ្ញុំទេ គ្រាន់តែកូនដួលសន្លប់ រួចយកទៅពេទ្យកំប្រង់ដេកព្យាបាល ០៤ថ្ងៃរបួសកូនខ្ញុំបានជាសះស្បើយហើយ របួសកូនខ្ញុំត្រូវចំថ្ងាសដេរ ១៧ថ្នេរ ។ មិនប្តឹងទាមទារអ្វីទេ របួសកូនខ្ញុំជាហើយ ។ ខ្ញុំទៅដល់កន្លែងកើតហេតុភ្លាមឈ្មោះ ផ សត វាគេចបាត់ ហើយព្រឹកឡើងឈ្មោះ ផ សត ចូលមកផ្ទះត្រូវគេចាប់ខ្លួនតែម្តង ។

## ព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ផ សត ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធប្រព្រឹត្ត នៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកា... ទង់

ស្នើសុំអោយតុលាការផ្តន្ទាទោសកំណត់ពី ០៨ខែ ដល់ ២៤ខែ ។

ឈ្មោះ ផ សត គ្មានសំណូមពរ ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ

-បានស្តាប់ចម្លើយអោយការរបស់ម្តាយជនរងគ្រោះ និង ជនរងគ្រោះ សាក្សី

-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់

-បានពិនិត្យ កំណត់ហេតុ ឯកសារ ភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង

## យល់ឃើញថា

-ពិតជាកើតមាននូវអំពើបង្ករបួសស្នាមដោយចេតនាមានអាវុធ នៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើបង្ករបួសស្នាមដោយចេតនាមានអាវុធ ដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ ផ សត វាយដោយពូថៅទៅលើក្បាលរបស់ឈ្មោះ ខ ត ជាកូនក្មួយរបស់ប្រពន្ធខ្លួនប្រាកដមែន ។

-អំពើដែលឈ្មោះ ផ សត បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ដូចមានបញ្ញត្តិក្នុងមាត្រា៤១ ត្រង់វាក្យខណ្ឌ ៣.៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជនជាប់ចោទជាសមត្ថជន គាត់មានអាយុ ៤២ឆ្នាំ មានស្មារតីជានាល្អ គាត់បានប្រព្រឹត្តអំពើដោយចេតនាដោយមានពូថៅជាឧបករណ៍វាយត្រូវចំថ្ងាសរបស់ឈ្មោះ ខ ត មួយពូថៅចំតបណ្តាល អោយឈ្មោះ ខ ត មានរបួសស្នាមបង្ហូរឈាម ដើម្បីព្យាបាល ១៧ថ្ងៃ ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ផ សត ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយរបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពីអំពើ ដែលខ្លួនបានប្រព្រឹត្តថា នៅថ្ងៃខែមិនចាំខ្លួនពិតជាបានវាយឈ្មោះ ខ ត ដែលត្រូវជាក្មួយបង្កើតរបស់ប្រពន្ធមួយពូថៅចំក្បាលហូរឈាមដួលដេកនឹងដី ។

-ចម្លើយអោយការរបស់ជនរងគ្រោះបានឆ្លើយបញ្ជាក់ថា ខ្លួនត្រូវឈ្មោះ សត វាយខ្លួនមួយពូថៅចំក្បាលបែកហូរឈាមដួលសន្លប់នៅនឹងដី ចម្លើយនេះស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទ ។

-ចម្លើយអោយការរបស់សាក្សីពន្លឺឈ្មោះ ម អ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ខ្លួនបានឮអ្នកជិតខាង

ស្រែកថា ឈ្មោះ ត វាយកូនខ្លួន ខ្លួនរត់ទៅមើល ឃើញកូនខ្លួនត្រូវរបួសត្រង់ថ្ងាសនាំទៅពេទ្យ១ដេរ ១៧ថ្នេរ ចម្លើយនេះស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទ និង ជនរងគ្រោះ ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានា ធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

-វត្ថុតាងមានពូថៅមួយ ជាឧបករណ៍ ដែលជនជាប់ចោទបង្កហេតុត្រូវរឹបអូសរួចបំផ្លាញចោល ។

## យល់ឃើញថា

-ឈ្មោះ ផ សត ជាជនមិនដែលមានទោសពីមុនមក គាត់បានបង្ករបួសស្នាមទៅលើកូនក្មួយរបស់គាត់ក៏រិតស្រាលតែមួយកន្លែងទេ គាត់មានលំនៅដ្ឋាន មុខរបរ គ្រួសារត្រឹមត្រូវជាហេតុអាចព្យួរខ្លះបាន ម្យ៉ាងទៀត ម្តាយរបស់ជនរងគ្រោះបានសំណូមពរអោយត្រាប្រណី និង ដោះលែងជនជាប់ចោទដោយមិនទារសំណងថ្លៃព្យាបាលរបួសកូនខ្លួនទេ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ ផ សត ដាក់ពន្ធនាគារកំណត់ ០៩ខែគត់ តែទោសនេះអោយឈ្មោះ ផ សត ទទួលទោសដូចខាងក្រោម :

-០៣ខែដាក់ពន្ធនាគារដោយគិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

-០៦ខែអោយឈ្មោះ ផ សត ទទួលទោសព្យួរ ដោយកំណត់រយៈពេលសាកល្បងកំណត់ ០៥ឆ្នាំគិតចាប់ពីក្រោយពេលកាត់សេចក្តីនេះតទៅ ។

ពីបទ **បង្ករបួសស្នាមដោយចេតនាមានអាវុធ** ប្រព្រឹត្តនៅភូមិតាំងយូរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោស មានបញ្ញត្តិក្នុងមាត្រា៤១ ត្រង់វាក្យខណ្ឌ៣.៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តាមបទបញ្ញត្តិមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

២-វត្ថុតាងមានពូថៅ ០១ដងធ្វើពីឈើប្រវែង ៧០ស.ម ផ្លែប្រវែង ១២ស.ម មុខផ្លែប្រវែង ៧ស.ម ត្រូវរឹបអូសរួចបំផ្លាញចោល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ។ ទុករយៈពេលប្តឹងទាស់ និង បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ** |
| [redacted] | [redacted] |

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រមអោយបេសរេច

តាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង. ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង. ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]